# តារាងសម្លាប់មេរោគ

## សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

### ការសម្លាប់មេរោគដោយប្រើជាតិអាល់កុល Ethyl ឬ Isopropyl កំហាប់ ៧០-៩០%

ជាតិអាល់កុល គឺជាសារធាតុសម្លាប់មេរោគកម្រិតមធ្យម។ ការសម្លាប់មេរោគកម្រិតមធ្យម អាចកម្ចាត់មេរោគភាគច្រើន (ដូចជា បាក់តេរី និងវីរុស) ប៉ុន្តែមិនអាចកម្ចាត់មេរោគបានទាំងអស់នោះទេ។ សម្ភារៈដែលអាចប៉ះពាល់នឹងស្បែក ដែលមានរបួសចំហ (ដូចជាស្នាមមុត ឬមុខរបួស) ឬភ្នាសរំអិល (ដូចជា ភ្នែក ច្រមុះ ឬមាត់) ឬសម្ភារៈដែលអាចបង្កឱ្យមានការដាច់រហែកស្បែក ចាំបាច់ត្រូវសម្លាប់មេរោគ ដោយប្រើសារធាតុសម្លាប់មេរោគដែលមានកម្រិតយ៉ាងហោចណាស់កម្រិតមធ្យម។ ឧទាហរណ៍នៃសម្ភារៈដែលត្រូវការការសម្លាប់មេរោគកម្រិតនេះ រួមមាន៖

- គម្របដាក់ទឹកថ្នាំសម្រាប់សាក់ (ប្រើបានតែម្តង)
- ជក់សម្រាប់ផាត់មុខ និងជក់គូរលម្អក្រចក/អាគ្រីលីក
- ដង្កៀបសម្រាប់ដកសក់ ឬសម្រាប់បិទរោមភ្នែកសិប្បនិម្មិត
- ឧបករណ៍កាត់ក្រចក
- ឧបករណ៍កាត់ស្បែកជុំវិញក្រចក
- ដែកខារក្រចក
- ប្រដាប់ម៉ាសាមុខ

| | |
|---|---|
| លក្ខខណ្ឌអាល់កុល | **អាល់កុលត្រូវតែ៖**<br>• មានកំហាប់ចាប់ពី ៧០%-៩០%។<br>◦ កំហាប់ជាតិអាល់កុលខ្ពស់ពេក (ដូចជា ៩៩%) មិនសូវមានប្រសិទ្ធភាពល្អទេ ដោយសារជាតិអាល់កុលត្រូវការបរិមាណទឹកក្នុងកម្រិតមួយដើម្បីដំណើរការ។<br>◦ ជាតិអាល់កុលត្រូវតែមានកំហាប់យ៉ាងហោចណាស់ ៧០% ដើម្បីឱ្យការសម្លាប់មេរោគមានប្រសិទ្ធភាព។<br>• មានលេខផលិតផលធម្មជាតិ (NPN) ដែលចេញដោយសុខាភិបាលកាណាដា និងបានបង្ហាញនៅលើស្លាកសញ្ញាផលិតផល។<br>• មិនហួសកាលបរិច្ឆេទប្រើប្រាស់ (សូមពិនិត្យមើលស្លាកសញ្ញា)។ |
| ការពិចារណាសម្រាប់ការប្រើប្រាស់ | **អាល់កុលត្រូវតែ៖**<br>• ចាក់ចូលទៅក្នុងធុងស្អាតដែលមានគម្រប ដើម្បីការពារកុំឱ្យវាស្ងួតលឿនពេក។<br>• **ហាមប្រើជារបៀបបាញ់** ដោយសារតែវាងាយហួត និងមិនអាចសម្លាប់មេរោគបានល្អ។<br>• **ហាមប្រើវាលើសពីមួយដង។** ត្រូវបោះវាចោលក្រោយប្រើរាល់ដង និងត្រូវយកអាល់កុលថ្មីមកប្រើលើកក្រោយៗទៀត។ ហាមចាក់ថែមទៅក្នុងទឹកអាល់កុលដែលប្រើរួច។<br>ឧបករណ៍ទាំងឡាយ ត្រូវដាក់ឲ្យលិចចូលក្នុងទឹកអាល់កុលទាំងស្រុង (ដោយមិនត្រូវឲ្យផ្នែកណាមួយនៃឧបករណ៍ មិនលិចនោះឡើយ)។ |
| រយៈពេលត្រាំវា | ១០ នាទី |
| របៀបសម្ងួត | លាងជម្រះ និងសម្ងួតវាដោយផ្លុំខ្យល់ |

## កំណត់សម្គាល់បន្ថែម៖

- លាងសម្អាតឧបករណ៍ជាមួយទឹកសាប៊ូ ទឹក និងជក់ មុនសម្លាប់មេរោគ។
- ប្រអប់ដែលដាក់ឧបករណ៍នោះ ត្រូវតែមានទំហំធំល្មមដើម្បីដាក់វាចុះ និងងាយស្រួលលាងវា និងត្រូវមានគំរបគ្របផង។
- ហាមលាយទឹកអាល់កុល ជាមួយផលិតផលលាងជម្រះអ្វីផ្សេង ឬលាយជាមួយគ្រឿងសម្លាប់មេរោគអ្វីផ្សេង ដ្បិតវាគ្រោះថ្នាក់។
- ដាក់ឈ្មោះរាល់ថ្នាំសម្លាប់មេរោគ និងដបដាក់ផលិតផលលាងជម្រះ។
- អនុវត្តតាមការណែនាំរបស់រោងចក្រ អំពីការប្រើប្រាស់ឧបករណ៍ ដើម្បីកុំឲ្យខូច។
- ហាមប៉ុនប៉ងលាយទឹកអាល់កុល ដែលធ្វើដោយខ្លួនឯង។

simcoe muskoka DISTRICT HEALTH UNIT

Revised: 2024-09-23